ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

លេខ : ៣៦៥៦/២៣ អ គ រ

ថ្ងៃ ច័ន្ទ ៩ កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការទទួលស្គាល់កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតទៅវិញទៅមក ក្នុងបណ្តាប្រទេសអាស៊ាន

(The ASEAN Authorized Economic Operators Mutual Recognition Arrangement - AAMRA)

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដល់សាធារណជន ឱ្យបានជ្រាបថា រដ្ឋបាលគយនៃបណ្តាប្រទេសជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បានចុះហត្ថលេខាទទួលស្គាល់កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតទៅវិញទៅមក (The ASEAN Authorized Economic Operator Mutual Recognition Arrangement - AAMRA) កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣។

AAMRA គឺជាការព្រមព្រៀងមួយគ្មានចំណងគតិយុត្តដើម្បីទទួលស្គាល់កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតទៅវិញទៅមកក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន។ ការព្រមព្រៀងនេះបានផ្តល់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែមជូនធុរជន ដែលត្រូវបានទទួលស្គាល់ថាជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតក្នុងបណ្តាប្រទេសអាស៊ាន ស្របតាមស្តង់ដារក្របខណ្ឌសុវត្ថិភាពរបស់អង្គការគយពិភពលោក (The World Customs Organisation SAFE Framework of Standards to Secure and Facilitate Global Trade - SAFE Framework) ព្រមទាំងរួមចំណែកបង្កើនសន្តិសុខនិងសុវត្ថិភាពនៃខ្សែច្រវាក់ផ្គត់ផ្គង់សាកល។

កន្លងមក អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានអនុវត្តប្រកបដោយជោគជ័យនូវយន្តការលើកទឹកចិត្តធុរជនល្អបំផុត ដើម្បីផ្តល់ការលើកទឹកចិត្តតាមរូបភាពផ្សេងៗដល់ធុរជនជាអ្នកនាំចេញ - អ្នកនាំចូល ដែលមានកម្រិតអនុលោមភាពខ្ពស់បំផុត ជាគំរូដល់ធុរជនផ្សេងទៀតនិងជាការចូលរួមលើកកម្ពស់សីលធម៌សារពើពន្ធក្នុងសង្គមធុរកិច្ចកម្ពុជា។ យន្តការនេះត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០១៣ និងត្រូវបានកំណត់ជាជំហានដំបូងនៃការអនុវត្ត កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតពេញ



អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

លេញមួយស្របតាមឧត្តមភាពនុវត្តអន្តរជាតិ។ រហូតមកដល់ពេលនេះមានក្រុមហ៊ុនចំនួន ៤៩ កំពុងទទួលបានការលើកទឹកចិត្តនានាក្នុងការបំពេញបែបបទគយ និងមានក្រុមហ៊ុនមួយចំនួនទៀតកំពុងដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតត្រូវបានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៣។ ក្រុមហ៊ុននានាដែលបានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យដែលបានកំណត់អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រនៅ អង្គភាពប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាប។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**